# កិច្ចតែងការបង្រៀន

- ❖ កាលបរិច្ឆេទ ថ្ងៃ.........ទី........ខែ.........ឆ្នាំ២០.................
- ❖ ប្រធានបទ ចម្រៀងនិងតន្ត្រី
- ❖ មុខវិជ្ជា សិក្សាសង្គម
- ❖ សកម្មភាពគោល ចម្រៀង
- ❖ ចំណងជើង រក្សាសុវត្ថិភាព
- ❖ ថ្នាកកម្រិត ខ្ពស់
- ❖ រយៈពេល ៣០នាទី

## I. វត្ថុបំណង

- ➢ **វិជ្ជាសម្បទា** កុមារប្រាប់បានពីឈ្មោះអ្នកនិពន្ធ ចំណងជើង អត្ថន័យនិងច្រៀងទៅតាមទំនុកបទ ចម្រៀងបានត្រឹមត្រូវតាមរយៈការណែនាំរបស់គ្រូ។
- ➢ **បំណិនសម្បទា** កុមារច្រៀងនិងធ្វើកាយវិការ បានត្រឹមត្រូវតាមរយៈការអនុវត្តផ្ទាល់។
- ➢ **ចរិយាសម្បទា** បណ្តុះស្មារតីកុមារក្លាហាន ឈ្លាសវៃរហ័សរហួន ប្រុងប្រយ័ត្ន សហការ ចងចាំ។

## II. សម្ភារឧបទេស

- ➢ **សម្ភារៈគ្រូ** អត្ថបទចម្រៀង
- ➢ **សម្ភារៈកុមារ** គ្មាន
- ➢ **ការរៀបចំ** កុមារអង្គុយរាងកន្លះរង្វង់

## III. ដំណើរនាំមេរៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពកុមារ |
|---|---|---|
| | **ជំហានទី១ លំនឹងថ្នាក់** | |
| -កូនមើលសមាជិកក្រុមមានបាត់ឬទេ? | -ការពិនិត្យអវត្តមាន | -កុមារឆ្លើយ |
| -កូនទាំងអស់គ្នាមានបានលេងជីអត់? | -ការពិនិត្យអនាម័យ | -កុមារឆ្លើយ |
| -ឲ្យកុមារធ្វើត្រាប់តាមសម្លេងសត្វ | -ប្រមូលអារម្មណ៍ | -កុមារត្រាប់សម្លេងសត្វ |
| | **ជំហានទី២ រំឭកមេរៀនចាស់** | |
| -គ្រូសួរចំណងជើងមេរៀនចាស់ | -សិក្សាសង្គម តុបតែងលម្អក្រមា | -កុមារឆ្លើយ |
| | **☼ ទំនាក់ទំនងមេរៀនថ្មី** | |
| -កូនធ្លាប់បានលេងអ្វីខ្លះ? | -បាល់ ទឹក | -កុមារឆ្លើយ |
| | **ជំហានទី៣ មេរៀនថ្មី** | |
| -អ្នកគ្រូច្រៀងនិងធ្វើកាយវិការឲ្យកុមារស្តាប់និងសង្កេតមួយចប់ | -ច្រៀងនិងធ្វើកាយវិការ | -កុមារស្តាប់ |
| -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេងទឹកតីរីករាយ ត្រូវមើលថែខ្លួនឯងផង។ | -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេងទឹកតីរីករាយ ត្រូវមើលថែខ្លួនឯងផង។ | |
| -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេងទូរស័ព្ទតីរីករាយ ត្រូវមើលថែខ្លួនឯងផង។ | -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេងទូរស័ព្ទតីរីករាយ ត្រូវមើលថែខ្លួនឯងផង។ | |
| -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ | -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ | |

| | | |
|---|---|---|
| ប្រើកាំបិតធ្វើម្ហូបយប់នេះ ត្រូវមើលថែខ្លួនឯងផង។ | ប្រើកាំបិតធ្វើម្ហូបយប់នេះ ត្រូវមើលថែខ្លួនឯងផង។ | |
| -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ ជិះកង់ទៅលេងមិត្តភក្តិ ត្រូវមើលថែខ្លួនឯងផង។ | -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ ជិះកង់ទៅលេងមិត្តភក្តិ ត្រូវមើលថែខ្លួនឯងផង។ | |
| -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេបថ្នាំឱ្យបានធូរស្បើយ ត្រូវមើលថែខ្លួនឯងផង។ | -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេបថ្នាំឱ្យបានធូរស្បើយ ត្រូវមើលថែខ្លួនឯងផង។ | |
| -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេងជាមួយឆ្កែឬឆ្មា ត្រូវមើលថែខ្លួនឯងផង។ | -រក្សាសុវត្ថិភាព សូមគិតពីអ្វីដែលអ្នកធ្វើ លេងជាមួយឆ្កែឬឆ្មា ត្រូវមើលថែខ្លួនឯងផង។ | |
| -បទនេះនិពន្ធ ដោយអង្គការវ៉ុមកកង់បី សម្រាប់កុមារ | -ប្រាប់ឈ្មោះអ្នកនិពន្ធ(ដោយអង្គការវ៉ុមកកង់បី សម្រាប់កុមារ) | -កុមារស្តាប់ |
| -គ្រូបំផុសរកចំណងជើងបទចម្រៀងនិង លំនាំបទ | -សិក្សាសង្ខេម ចម្រៀងបទ រក្សាសុវត្ថិភាព | -កុមារឆ្លើយ |
| -គ្រូពន្យល់ន័យនៃពាក្យពិបាក និងអត្ថន័យ ចម្រៀង | -ពន្យល់ន័យនៃពាក្យពិបាកនិងអត្ថន័យ | -កុមារស្តាប់ |
| -សុវត្ថិភាព: ការមានសួស្តី ការប្រកបដោយ សេចក្តីសុខ។ | -សុវត្ថិភាព: ការមានសួស្តី ការប្រកបដោយសេចក្តីសុខ។ | |
| -ថែ: គ្រប់គ្រង, រក្សា, បីបាច់។ | -ថែ: គ្រប់គ្រង, រក្សា, បីបាច់។ | |
| -ធូរស្បើយ:ស្រាក, ស្បើយ ជំងឺ))។ | -ធូរស្បើយ:ស្រាក, ស្បើយ ជំងឺ))។ | |
| -បទនេះអប់រំឲ្យកូនទាំងអស់ដឹងអំពីផល ប្រយោជន៍ និងគ្រោះថ្នាក់នៃការលេងនិងប្រើ ប្រាស់វត្ថុនានា ។ | -បទនេះអប់រំឲ្យកូនទាំងអស់ដឹងអំពីផលប្រយោជន៍ និងគ្រោះថ្នាក់នៃការលេងនិងប្រើប្រាស់វត្ថុនានា ។ | -កុមារស្តាប់ |
| -គ្រូអោយកុមារអានអត្ថបទចម្រៀងមួយឃ្លា ម្តងៗរហូតដល់ចប់ | -អានអត្ថបទចម្រៀងមួយឃ្លាម្តងៗរហូតដល់ចប់ | -កុមារស្តាប់និងអាន |
| -គ្រូឲ្យកុមារកំដៅសម្លេងដោយធ្វើឡាឡាៗ តាមរលកសម្លេង ឬតាមលំនាំបទចម្រៀង | -កំដៅសម្លេងដោយធ្វើឡាឡាៗ តាមរលកសម្លេង ឬតាមលំនាំបទ ចម្រៀង | -កុមារកំដៅសម្លេងដោយ ធ្វើឡាឡាៗ |
| -គ្រូនាំកុមារច្រៀង និងធ្វើកាយវិការមួយឃ្លា ម្តងៗរហូតដល់ចប់ | -នាំកុមារច្រៀង និងធ្វើកាយវិការ មួយឃ្លាម្តងៗ រហូតដល់ចប់ | -កុមារច្រៀង និងធ្វើកាយ វិការ |
| -គ្រូនិងកុមារច្រៀង និងធ្វើកាយវិការសារ ឡើងវិញមួយចប់ | -ច្រៀងនិងធ្វើកាយវិការសារឡើងវិញមួយចប់ | -កុមារច្រៀងនិងធ្វើកាយ វិការសារឡើងវិញ១ចប់ |
| -គ្រូច្រៀងបំបាត់ពាក្យ កុមារច្រៀងបំពេញ ពាក្យ | -ច្រៀងបំពេញពាក្យ | -កុមារច្រៀងបំពេញពាក្យ |
| -គ្រូច្រៀងតិចៗ កុមារច្រៀងឮៗមួយចប់ | | -កុមារច្រៀងឮ |
| | **ជំហានទី៤ ពង្រឹងចំណេះដឹង** | |
| -តើអំបាញ់មិញកូនបានច្រៀងបទអ្វី? | -សិក្សាសង្ខេម ចម្រៀងបទ រក្សាសុវត្ថិភាព | -កុមារឆ្លើយ |
| -កូនណាអាចឡើងច្រៀងម្តងទៀតបាន? | -ឡើងច្រៀង១ឬ២នាក់ | -កុមារច្រៀង១ឬ២ នាក់ |

| | | |
|---|---|---|
| -ចាំ! កូនៗទាំងអស់គ្នាធ្វើបានល្អណាស់ ថ្ងៃក្រោយធ្វើឲ្យបានល្អជាងនេះណាំ..! ពេលត្រឡប់ទៅផ្ទះវិញកូនច្រៀងចម្រៀងនេះឲ្យប៉ាម៉ាក់កូនស្តាប់ផង។ | **ជំហានទី៥ បណ្តាំផ្ញើ**<br>-លើកសរសើររួម ឬក្រុម | -ស្តាប់ |

សុខារាមថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

គ្រូប្រចាំថ្នាក់

**តាន់ រចនា**

បានឃើញនិងឯកភាព

**នាយិកាសាលា**